សង្ខេបសំរាប់
# គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សំរាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ១២

# ផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រ លើទ្រព្យសម្បត្តិរបស់គ្រួសារ[១]

*ដោយ តុង គឹមស៊ុន[២] ហែម សុបិត្ត[២] និង* Paulo SANTOS[៣]

## ខ្លឹមសារសំខាន់ៗ

- គ្មានភស្តុតាងណាបង្ហាញថា គ្រួសារដែលដាំដុះលើក្បាលដីមានការស្រោចស្រព គឺមានទ្រព្យសកម្មជាប់លាប់ សត្វចិញ្ចឹម បរិក្ខារកសិកម្ម គោ និងក្របី ឬសត្វអូសទាញ ច្រើនជាងគ្រួសារដែលដាំដុះលើក្បាលដីគ្មានប្រព័ន្ធស្រោចស្រពនោះទេ។
- ធនធានមនុស្ស រួមចំណែកច្រើនណាស់ដល់ការបង្កើនទ្រព្យសកម្មជាប់លាប់។
- ចំនួនសមាជិកគ្រួសារ មានទំនាក់ទំនងវិជ្ជមាន ជាមួយចំនួនសត្វចិញ្ចឹម គោក្របី និងសត្វអូសទាញ ។ ប៉ុន្តែទ្រព្យទាំងអស់នេះ អាចធ្លាក់ចុះវិញ ប្រសិនបើគ្រួសារមានសមាជិកសរុបលើសពី ៧ ទៅ ៨នាក់។

## បញ្ហាចោទ

រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ថា ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលដំណើរការល្អ គឺជាលក្ខខណ្ឌចាំបាច់ដើម្បីសម្រេចតាមគោលដៅជាតិនៃ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ហេតុនេះ ការស្តារឡើងវិញ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តបន្ថែម ត្រូវបានកំណត់ជាសមាសភាគដ៏សំខាន់បំផុតមួយ ដើម្បីសម្រេចតាមគោលដៅជាតិឲ្យបាន (RGC,2009)។ នៅអំឡុងឆ្នាំ២០០៦ ដល់ ២០០៨ ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM) បានអនុវត្តគម្រោងប្រព័ន្ធធារាសាស្ត្រចំនួន ១៤៤ ដើម្បីផ្តល់ទឹកស្រោចស្រពដល់ផ្ទៃដី ២៦៧.២២៤ហិកតា (RGC, 2009)។ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ រដ្ឋាភិបាលកម្ពុជានឹងបន្តផ្តល់អាទិភាពដល់ការស្តារ ថែទាំ សាងសង់ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើនផលិតកម្មកសិកម្ម។ រដ្ឋាភិបាលមានទិសដៅបង្កើនប្រសិទ្ធភាពការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រតាមរយៈការដាក់អនុវត្តគោលនយោបាយអភិវឌ្ឍន៍ និងគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រប្រកបដោយការចូលរួម និងការបង្កើតសហគមន៍កសិករប្រើប្រាស់ទឹក។

ប្រព័ន្ធស្រោចស្រពផ្តល់អត្ថប្រយោជន៍ជាច្រើន ដែលអាចរួមចំណែកដល់ ការកាត់បន្ថយភាពក្រីក្រ និងកំណើនសេដ្ឋកិច្ច (ឧ. Dillon 2011, Hussain 2007, Hussain & Hanjra 2004) ប៉ុន្តែគំនិតនេះត្រឹមត្រូវបានដល់កម្រិតណាគឺនៅមិនទាន់មានការសិក្សា ឲ្យបានទូលំទូលាយនៅឡើយទេ។ កង្វះខាតចំណេះដឹងពីរឿងនេះ បានរាំងស្ទះដល់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងការធ្វើសេចក្តីសម្រេចចិត្តដោយមានព័ត៌មានគ្រប់គ្រាន់ ពីជម្រើសដ៏ប្រសើរលើវិនិយោគខាង ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រដើម្បីទទួលបានផលប្រយោជន៍បន្ថែមច្រើនបំផុត ហើយសម្រេចបានតាមគោលដៅសេដ្ឋកិច្ច និងសង្គមកិច្ចរបស់

---

១ អត្ថបទសង្ខេបគោលនយោបាយនេះ ផ្អែកលើឯកសារពិភាក្សារបស់ CDRI រៀបចំដោយ តុង គឹមស៊ុន ហែម សុបិត្ត និង Paulo S. (ចេញផ្សាយនាពេលឆាប់ៗខាងមុខនេះ) ស្តីពី *ផលប៉ះពាល់នៃប្រព័ន្ធធារាសាស្ត្រលើទ្រព្យសម្បត្តិគ្រួសារ។* ឯកសារពិភាក្សានេះ បង្ហាញពីលទ្ធផលស្រាវជ្រាវក្នុងសមាសភាគសេដ្ឋកិច្ចនៃ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP) ដែលជាគម្រោងរយៈពេល៥ឆ្នាំ ទទួលមូលនិធិពីទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) សំដៅជួយកែលម្អការប្រើប្រាស់ និងគ្រប់គ្រងធនធានទឹក ដើម្បីបង្កើនផលិតកម្មកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តភាព។

២ កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ នៃវិទ្យាស្ថាន CDRI ។

៣ មហាវិទ្យាល័យកសិកម្ម ស្បៀងអាហារ និងធនធានធម្មជាតិ នៃសាកលវិទ្យាល័យស៊ីដនី។

តារាង១: ទ្រព្យសកម្មរបស់គ្រួសារ គិតតាមស្ថានភាពធារាសាស្ត្រ

| | គ្មានក្បាលដីស្រោចស្រព | ក្បាលដីស្រោចស្រព <=50% | ក្បាលដីស្រោចស្រព >50% | ANOVA | | សរុប |
|---|---|---|---|---|---|---|
| | | | | ស្ថិតិ F | Significance level | |
| ចំនួនគ្រួសារ | 17 | 61 | 142 | | | 220 |
| សន្ទស្សន៍ទ្រព្យសកម្មជាប់លាប់ | | | | | | |
| ឆ្នាំ 2008 | -0.56 | 0.07 | 0.07 | 1.15 | 0.317 | 0.02 |
| ឆ្នាំ 2010 | -0.27 | 0.22 | 0.18 | 0.64 | 0.526 | 0.16 |
| សន្ទស្សន៍សត្វចិញ្ចឹម | | | | | | |
| ឆ្នាំ 2008 | -0.32 | -0.22 | 0.11 | 2.81 | 0.062 | -0.01 |
| ឆ្នាំ 2010 | -0.68 | -0.47 | -0.45 | 0.92 | 0.401 | -0.48 |
| សន្ទស្សន៍បរិក្ខារកសិកម្ម | | | | | | |
| ឆ្នាំ2008 | -0.34 | 0.05 | 0.00 | 0.59 | 0.553 | -0.01 |
| ឆ្នាំ 2010 | -0.16 | 0.09 | 0.08 | 0.27 | 0.760 | 0.07 |
| គោ និងក្របី | | | | | | |
| ឆ្នាំ 2008 | 3.35 | 3.54 | 3.82 | 0.37 | 0.688 | 3.70 |
| ឆ្នាំ 2010 | 2.94 | 3.38 | 3.08 | 0.34 | 0.710 | 3.15 |
| សត្វអូសទាញ | | | | | | |
| ឆ្នាំ 2008 | 1.59 | 1.56 | 1.89 | 0.70 | 0.499 | 1.77 |
| ឆ្នាំ 2010 | 1.59 | 1.20 | 1.27 | 0.74 | 0.477 | 1.28 |

រដ្ឋាភិបាលកម្ពុជា។ ការសិក្សាស្រាវជ្រាវឯកសារបង្ហាញថា មិនទាន់មានការសិក្សាណាមួយ ដែលបានពិនិត្យជាក់ស្តែង នៅកម្ពុជាពី ផលប៉ះពាល់នៃវត្តមានប្រព័ន្ធធារាសាស្ត្រ ទៅលើស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ដោយប្រើសូចនាករមួយចំនួន ដូចជា ទ្រព្យសកម្ម ប្រាក់ចំណូល អាហារូបត្ថម្ភ សុខភាព និងភាពក្រីក្រ នៅឡើយទេ។ ដើម្បីបំពេញកង្វះចំណេះដឹងនេះ ការសិក្សានេះ ព្យាយាមវាស់វែងពីឥទ្ធិពលនៃប្រព័ន្ធធារាសាស្ត្រ ទៅលើទ្រព្យសម្បត្តិរបស់គ្រួសារ មានជាអាទិ៍ ទ្រព្យសកម្មជាប់លាប់ បរិក្ខារកសិកម្ម គោក្របី និងសត្វអូសទាញ[៤]។

## ករណីសិក្សា

អត្ថបទសង្ខេបគោលនយោបាយនេះ បង្ហាញពីលទ្ធផលស្រាវជ្រាវសំខាន់ៗរបស់ CDRI ក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក (WRMRCDP)[៥] តាមរយៈអង្កេតគ្រួសារ នៅក្នុង ១០ ប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្ត ៣ (កំពង់ចាម កំពង់ធំ និង ពោធិ៍សាត់) ក្នុងតំបន់អាងទន្លេសាប នៅឆ្នាំ២០០៨-២០១០។ ក្នុងនេះគេបានជ្រើសរើសដោយចៃដន្យ ៣០ គ្រួសារពីក្នុងគម្រោងនីមួយៗ មកធ្វើសម្ភាសន៍មូលដ្ឋាន ដើម្បីទទួលបានព័ត៌មានពីលក្ខណៈគ្រួសារ អាជីវកម្មគ្រួសារ លក្ខណៈដីលំនៅឋាននិងដីកសិកម្ម សត្វចិញ្ចឹម និងទ្រព្យមូលធនដទៃទៀត។ អង្កេតតាមដានបន្តទៀត រួមមាន ការធ្វើសម្ភាស ២៣៥គ្រួសារក្នុងរដូវវស្សាឆ្នាំ២០០៨ និង ២០០៩ និង ២២០គ្រួសារ ក្នុងរដូវប្រាំងឆ្នាំ២០០៨ និង ២០០៩។ អង្កេតមូលដ្ឋានទី២ បានធ្វើឡើងនៅខែសីហា ២០១០ ដើម្បីធ្វើបច្ចុប្បន្នភាពទិន្នន័យអំពី លក្ខណៈគ្រួសារ សត្វចិញ្ចឹម និងទ្រព្យមូលធនដទៃទៀត។

---

៤ សត្វអូសទាញ សំដៅលើ គោក្របីទាំងអស់របស់គ្រួសារមួយ ដែលសម្រាប់ប្រើក្នុងសកម្មភាពកសិកម្ម។

៥ WRMRCDP មានសមាសភាគ ៣៖ សមាសភាគរូបវន្ត សមាសភាគអភិបាលកិច្ច និងសមាសភាគសេដ្ឋកិច្ច (CDRI 2010)។

ការសិក្សាខុសៗគ្នា បានកំណត់អថេរធារាសាស្ត្រខុសៗគ្នា៖ ឧទាហរណ៍ ប្រព័ន្ធស្រោចស្រពនៅតាមក្បាលដីនីមួយៗ ការស្រោចស្រពយកទឹកពីលើផ្ទៃដី និងក្រោមដី និងទំហំដីមានការស្រោចស្រព គិតក្នុងមនុស្សម្នាក់ (Wokker et al. ចេញផ្សាយនាពេលខាងមុខ, Huang et al. 2006, Zhou et al. 2009)។ ក្នុងការសិក្សានេះ អថេរធារាសាស្ត្រ ត្រូវបានកំណត់ថាជា សមាមាត្រនៃក្បាលដីមានប្រព័ន្ធស្រោចស្រព ធៀបនឹងក្បាលដីសរុបក្នុងមួយគ្រួសារ។ យោងតាមនិយមន័យអថេរធារាសាស្ត្រនេះ និងកម្មវត្ថុនៃការសិក្សា ចំនួនប្រជាជនគំរូតាងសរុបប្រើប្រាស់ក្នុងការវិភាគ បានកាត់បន្ថយមកត្រឹម ២២០គ្រួសារ។

## លទ្ធផលសំខាន់ៗ

ការវិភាគបែបពិពណ៌នាលើ ទិន្នន័យអង្កេតបង្ហាញថា ទ្រព្យសកម្មជាប់លាប់ និងបរិក្ខារកសិកម្ម កើនឡើងក្នុងរយៈពេលសិក្សាពីឆ្នាំ២០០៨ ដល់ ២០១០ ប៉ុន្តែចំនួនសត្វចិញ្ចឹម គោក្របី និងសត្វអូសទាញ បានធ្លាក់ចុះក្នុងគ្រប់ក្រុមគ្រួសារ (ឧ. ក្រុមគ្មានក្បាលដីស្រោចស្រព ក្រុមមានក្បាលដីស្រោចស្រពតិចជាង៥០% និងក្រុមមានក្បាលដីស្រោចស្រពច្រើនជាង៥០%)។ ការថយចុះចំនួនសត្វចិញ្ចឹម និងគោក្របី ក្នុងចំណោមគ្រួសារមានក្បាលដីស្រោចស្រពច្រើនជាង ៥០% វាមានកម្រិតខ្លាំងជាង គ្រួសារដែលគ្មានដីស្រោចស្រព។ ផ្ទុយទៅវិញ កំណើនទ្រព្យសកម្មជាប់លាប់ និងបរិក្ខារកសិកម្ម ក្នុងគ្រួសារគ្មានដីស្រោចស្រព វាមានកម្រិតខ្ពស់ជាង គ្រួសារមានដីស្រោចស្រព។ ចំនួនសត្វអូសទាញរបស់ គ្រួសារដែលមានក្បាលដីស្រោចស្រពតិចជាង ៥០% និងគ្រួសារមានច្រើនជាង ៥០% ធ្លាក់ចុះយ៉ាងគំហុក ប៉ុន្តែវានៅថេរសម្រាប់គ្រួសារគ្មានក្បាលដីស្រោចស្រព (ក្រាហ្វិក ១)។

ទោះជាតម្លៃមធ្យមនៃទ្រព្យសកម្មនីមួយៗ ប្រែប្រួលខុសគ្នាក្នុងចំណោមគ្រួសារទាំងបីក្រុមក្តី ក៏វិធីសាស្ត្រវិភាគវ៉ារីយង់ (ANOVA)[៦] បង្ហាញថា គ្មានការខុសគ្នាគួរឲ្យកត់សម្គាល់ខាងស្ថិតិទេ រវាងតម្លៃមធ្យម (means) សម្រាប់រាល់ទ្រព្យសកម្មទាំងអស់ក្នុងឆ្នាំទាំងពីរ លើកលែងតែសម្រាប់សត្វចិញ្ចឹមក្នុងឆ្នាំ២០០៨។

គួរកត់សម្គាល់ថា ការវិភាគបែបពិពណ៌នា អាចបង្ហាញត្រឹមតែទំនាក់ទំនងធម្មតា រវាងអថេរធារាសាស្ត្រ និងទ្រព្យសកម្មគ្រួសារប៉ុណ្ណោះ ប៉ុន្តែការប្រែប្រួលនៃទ្រព្យ

ក្រាហ្វិក ១: បម្រែបម្រួលនៃទ្រព្យសកម្មក្នុងគ្រួសារ (២០០៨-២០១០)




៦ Anova ជាវិធីសាស្ត្រសម្រាប់កំណត់ថា តើមានការខុសគ្នាគួរកត់សម្គាល់ឬទេ រវាង មធ្យម (means) នៃក្រុមជាច្រើន (ចាប់ពី៣ក្រុមឡើងទៅ)។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
(៨៥៥-២៣) ៨៨០-៧៣៤
e-mail: cdri@cdri.org.kh
Website: http://www.cdri.org.kh

សកម្មគ្រួសារ អាចជាប់ទាក់ទងនឹងកត្តាជាច្រើនទៀត ដូចជាឱកាសខាងសេដ្ឋកិច្ច និង/ឬលក្ខណៈគ្រួសារជាដើម។ ដើម្បីដោះស្រាយចំណុចខ្សោយនៃការវិភាគបែបពិពណ៌នា ការសិក្សានេះ បានប្រើវិធីសាស្ត្រសេដ្ឋកិច្ចមាត្រសាស្ត្រ[៧] ហើយរកឃើញលទ្ធផលថា៖

- ការទទួលបានក្បាលដីស្រោចស្រពកាន់តែធំ មិនមានឥទ្ធិពលវិជ្ជមានអ្វីគួរកត់សម្គាល់ទេទៅលើ ការបង្កើនទ្រព្យសកម្មគ្រួសារ។
- ធនធានមនុស្ស រួមចំណែកច្រើនណាស់ដល់កំណើនទ្រព្យសកម្មជាប់លាប់។
- ចំនួនសមាជិកគ្រួសារ មានទំនាក់ទំនងវិជ្ជមានជាមួយចំនួនសត្វចិញ្ចឹម គោក្របី និងសត្វអូសទាញ ប៉ុន្តែទ្រព្យទាំងនេះច្រើនតែថយចុះវិញ ប្រសិនបើគ្រួសារមានសមាជិកសរុបលើសពី ៧ ទៅ ៨នាក់។

## លទ្ធផលសម្រាប់គោលនយោបាយ

លទ្ធផលសំខាន់ៗសម្រាប់គោលនយោបាយ ដែលផុសចេញពីការសិក្សានេះ មានដូចតទៅ៖

- គួរផ្តោតការយកចិត្តកាន់តែច្រើន លើការថ្លឹងថ្លែងឲ្យមានតុល្យភាពល្អរវាង ការកែលម្អប្រសិទ្ធភាពប្រព័ន្ធធារាសាស្ត្រ ជាអាទិ៍ ការផ្គត់ផ្គង់ទឹកបានទាំងរដូវវស្សា និងរដូវប្រាំង ការបែងចែកទឹកប្រកបដោយសមធម៌ ការកំណត់កម្រិតទឹកសមស្របនៅក្នុងក្បាលដីដាំដុះ ហើយនិងការពង្រីកដែនគ្របដណ្តប់នៃប្រព័ន្ធធារាសាស្ត្រ។
- ការគួបផ្សំគ្នានូវ ការបង្កើនវិនិយោគទៅលើធនធានមនុស្ស និងទៅលើហេដ្ឋារចនាសម្ព័ន្ធទាំងពីរមុខ ទំនងមានឥទ្ធិពលខ្លាំងទៅលើ ការលើកកម្ពស់ជីវភាពរស់នៅ ស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច និងការបង្កើនទ្រព្យសកម្មគ្រួសារ ជាងវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធតែមួយមុខ។

## ឯកសារយោង


Cambodia Development Resource Institute (2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*, Working Paper No. 48 (Phnom Penh: CDRI)

Dillon, A. (2011), "The effect of Irrigation on Poverty Reduction, Asset Accumulation, and Informal Insurance: Evidence from Northern Mali", *World Development*, doi:10.1016/j.worlddev.2011.04.006 (accessed 27 May 2011)

Food and Agriculture Organisation (2005), *The Future of Large Rice-Based Irrigation Systems in Southeast Asia* (Bangkok: FAO Regional Office for Asia and the Pacific)

Huang, Q., S. Rozelle, B. Lohmar, J. Huang, & J. Wang (2006), "Irrigation, Agricultural Performance and Poverty Reduction in China", *Food Policy*, Vol. 31, Issue 1, pp. 30-52

Hussain, I. & M. Hanjra (2004), "Irrigation and Poverty Alleviation: Review of the Empirical Evidence", *Irrigation and Drainage*, Vol. 53, Issue 1, pp. 1-15

Hussain, I. (2007), "Poverty-Reducing Impact of Irrigation: Evidence and Lessons", *Irrigation and Drainage*, Vol. 56, pp. 147-164

Royal Government of Cambodia (2009), National Strategic Development Plan 2009-2013 (Phnom Penh: RGC)

Tong K., Hem S. & Santos P. (forthcoming), *The Impact of Irrigation on Household Assets, CDRI Working Paper* (Phnom Penh: CDRI)

Wokker C., Santos P. & Ros B. (forthcoming), *Irrigation Water Productivity in Cambodian Rice Systems*, CDRI Working Paper (Phnom Penh: CDRI)


[៧] វិធីសាស្ត្រ Ordinary Least Squared (OLS), Two Stage Least Squared (TSLS) និង Limited Information Maximum Livelihood (LIML) ត្រូវបានប្រើប្រាស់។